# អង្គការទស្សនៈពិភពលោកអន្តរជាតិ

# គោលនយោបាយស្តីពីការការពារកុមារ

# គោលការណ៍ក្រមចរិយាធម៌សំរាប់ដៃគូ និងអ្នកម៉ៅការ

អង្គការទស្សៈពិភពលោកអន្តរជាតិគឺជា ដៃគូអន្តរជាតិនៃគ្រិស្ទបរិស័ទ ដែលមានបេសកកម្មដើរតាមព្រះជាម្ចាស់ព្រះយេស៊ូគ្រិស្តជាព្រះសង្គ្រោះដោយធ្វើការជាមួយជនក្រក្រី និងជនដែលរងការគាបសង្កត់ ដើម្បីបង្កើតឲ្យមានការផ្លាស់ប្រែដល់មនុស្សជាតិ ស្វែងរកភាពយុត្តិធម៌ និងធ្វើបន្ទាល់ពីដំណឹងល្អនៃនគរព្រះ។

ទស្សនៈវិស័យរបស់យើងគឺ ចង់ឃើញកុមារគ្រប់រូបមានជីវិតពេញបរិបូរណ៍ សេចក្តីអធិស្ឋានរបស់យើងសូមឲ្យទឹកចិត្តមនុស្សគ្រប់រូបមានឆន្ទៈដើម្បីសំរេចបំណងនេះ។

ការការពារកុមារ និងសិទ្ធិកុមារគឺជា គ្រឹត្យក្រមដ៏ចំបងរបស់អង្គការទស្សៈពិភពលោកអន្តរជាតិ។ អង្គការទស្សៈពិភពលោកអន្តរជាតិ លើកកម្ពស់អនុសញ្ញាស្តីពីសិទ្ធិកុមារដែលចែងថា កុមារទាំងឡាយមានសិទ្ធិស្មើគ្នាក្នុងការរស់រាន ការថែទាំសុខភាព ការអប់រំ ការការពារ និងការចូលរួមដោយគ្មានការរើសអើងទោះបីជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ ក្រមចរិយាធម៌នេះ ផ្តល់ការគាំទ្រ និងធ្វើឲ្យមានជាដរាបលើកម្មវិធី និងគោលនយោបាយរបស់អង្គការទស្សៈពិភពលោកអន្តរជាតិទាំងអស់ដែលផ្តោះសំដៅទៅរកការសម្រេចឲ្យបាននូវទស្សនៈវិស័យរបស់យើងសំរាប់កុមារគ្រប់រូបមានជីវិតប្រកបដោយភាពពេញបរិបូរណ៍។ ដូច្នេះគ្រប់អង្គភាពដៃគូ និងអ្នកម៉ៅការទាំងអស់របស់អង្គការទស្សៈពិភពលោកអន្តរជាតិត្រូវបានរំពឹងឲ្យចូលរួមក្នុងការការពារកុមារដោយតម្រូវឲ្យគោរពតាមក្រមចរិយាធម៌នេះគ្រប់ពេលវេលា។

ការរំលោភបំពានផ្លូវភេទលើកុមារគឺជា បទឧក្រិដ្ឋ ហើយជានិច្ចកាលនឹងត្រូវបានរាយការណ៍ទៅអាជ្ញាធរដែលពាក់ព័ន្ធ។ ឥរិយាបថមិនសមរម្យទៅលើកុមារ រាប់បញ្ចូលទាំងការមិនគោរពតាមក្រមចរិយាធម៌របស់អង្គការទស្សៈពិភពលោកអន្តរជាតិ ឬការរំលោភបំពានផ្លូវភេទលើកុមារគឺជា មូលដ្ឋាននៃការបញ្ចប់កិច្ចសន្យានេះ។

ក្នុងករណីសាមីជនចុះហត្ថលេខា ស្ថាប័ន ឬបុគ្គលិកដែលជាអ្នកតំណាងក្នុងការផ្តល់សេវានានាបានប្រព្រឹត្តល្មើសលើក្រមចរិយាធម៌នេះ អង្គការទស្សៈពិភពលោកអន្តរជាតិនឹង ធ្វើការបញ្ចប់កិច្ចសន្យាជាបន្ទាន់។

១. ដៃគូ ឬអ្នកម៉ៅការរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិត្រូវតែយកចិត្តទុកដាក់ចំពោះអាកប្បកិរិយាសមរម្យក្នុងការទំនាក់ទំនងជាមួយកុមារ។

២. ដៃគូ ឬអ្នកម៉ៅការរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ មិនត្រូវជួលកុមារមកធ្វើការឡើយ

៣. ដៃគូ ឬអ្នកម៉ៅការរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ មិនត្រូវប្រើពាក្យសំដីដែលមិនសមរម្យដូចជាការប្រមាថមើលងាយ ការបៀតបៀនផ្លូវភេទ ការអញ្ជើញកុមារ ឬការប្រើអំណាច និងឥទ្ធិពលដើម្បីបញ្ចុះបញ្ចូលកុមារឲ្យប្រព្រឹត្តអំពើអានាចារសំរាប់បំពេញចំណង់ផ្លូវភេទរបស់មនុស្សធំឡើយ។

៤. ដៃគូ ឬអ្នកម៉ៅការរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ មិនត្រូវប្រើវត្ថុដែលស្តែងឲ្យឃើញពីរូបភាពសកម្មភាពផ្លូវភេទ ឬធ្វើឲ្យកុមារមានអារម្មណ៍មិនកក់ក្តៅឡើយ ដូចជារូបភាពប្រមាថមើលងាយ រូបថតអាសអាភាសគ្រប់ទម្រង់ គំនូរកំប្លែង ឬកាយវិការអាសអាភាស សំនេរទំនាក់ទំនងដែលមានភាសាអាសអាភាសគ្រប់ប្រភេទ។

៥. ដៃគូ ឬអ្នកម៉ៅការរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ មិនត្រូវធ្វើឲ្យមានការឈឺចាប់ផ្នែករាងកាយ ឬបង្កឲ្យមានរបួសស្នាមដល់កុមារ ឬក៏ធ្វើសកម្មភាពរំលោភបំពានកុមារឡើយ។

៦. ដៃគូ ឬអ្នកម៉ៅការរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ មិនត្រូវផ្លាស់ប្តូរព័ត៌មានផ្ទាល់ខ្លួនជាមួយកុមារ (ដូចជា អាសយដ្ឋាន លេខទូរសព្ទ័ សារអេឡិចត្រូនិច បណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក ឬបណ្តាញព័ត៌មានសង្គមដទៃទៀត)ឡើយ។

៧. ដៃគូ ឬអ្នកម៉ៅការរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិនឹងមិនបង្ហោះរូបថតរបស់កុមារវិដេអូ និងព័ត៌មានផ្ទាល់ខ្លួនរបស់កុមារ (ដូចជានាមត្រកូល លេខសំគាល់របស់កុមារល័ក្ខខ័ណ្ឌការពិនិត្យព្យាបាលលំអិត ការបង្ហាញពីលក្ខណៈរង្វាស់រង្វាល់របស់កុមារដូចជាកំពស់ គីឡូកំរិតបញ្ញា អាសយដ្ឋានស្នាក់នៅរបស់កុមារ ឈ្មោះសាលារៀន អាសយដ្ឋានសាលារៀន កន្លែងសំគាល់សហគមន៍ និងភូមិ កន្លែងធ្វើការរបស់ឪពុកម្តាយ) ក្នុងគេហទំព័រហ្វេសប៊ុកផ្ទាល់ខ្លួនរបស់ពួកគេ ឬបណ្តាយព័ត៌មានសង្គមដទៃទៀត។

៨. ដៃគូ ឬអ្នកម៉ៅការរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ គួរស្លៀកពាក់សមរម្យពេលចុះទស្សនកិច្ចកុមារ ឬសហគមន៍ ឬគម្រោង អង្គការទស្សនៈពិភពលោកកអន្តរជាតិស្នើរសុំឲ្យ

អ្នកដែលចុះទស្សនកិច្ចស្លៀកសំលៀកបំពាក់ដែលសមរម្យតាមទំនៀមទំលាប់ដែលអាចទទួលយកបាន ដូចជាមិនស្លៀកសំលៀកបំពាក់ខ្លី សំពត់ខ្លី និងសំលៀកបំពាក់ស្តើង។ គួរស្លៀកសំលៀកបំពាក់វែង យ៉ាងហោចណាស់សំពត់ក្រោមជង្គង់ ខោវែង និង ខោខូវប៊យវែង។

៩. ដៃគូ ឬអ្នកម៉ៅការរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ត្រូវបង្ហាញការគោរពចំពោះទំនៀមទំលាប់ និងសិទ្ធិមនុស្ស។

១០. ប្រសិនណាបើសង្ស័យថាមានកាសង្ស័យណាមួយនៃការធ្វើបាប រំលោភបំពាន ឬបង្កគ្រោះថ្នាក់ដល់កុមារនៅក្នុងតំបន់ការងាររបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ដៃគូ ឬអ្នកម៉ៅការគួររាយការណ៍ជាបន្ទាន់ទៅកាន់បុគ្គលិករបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ឬទូរស័ព្ទទាន់ហេតុការណ៍ផ្នែកសុវត្ថិភាពកុមារ (+៨៥៥ ០១៧ ៦៦៦ ៧១៧ ឬ +៨៥៥ ០១៧ ៦៦៦ ៨៧៣)។

ការមិនប្រតិបត្តិតាមគោលការណ៍ក្រមចរិយាធម៌នេះនឹងត្រូវចាត់វិធានការណ៍យ៉ាងតឹងរឹង។ អង្គការទស្សនៈពិភពលោកអន្តរជាតិសូមរក្សាសិទ្ធិក្នុងការបញ្ជូនករណីបទល្មើសព្រហ្មទណ្ឌទៅកាន់នគរបាល និងសេវាសង្គមផ្សេងៗ។

ខ្ញុំបានអាន បានយល់ ហើយប្តេជ្ញាថានឹងប្រកាន់ខ្ជាប់តាមគោលការណ៍ក្រមចរិយាធម៌របស់អង្គការទស្សនៈពិភពលោកអន្តរជាតិជានិច្ច។

| ឈ្មោះ | ហត្ថលេខា និងកាលបរិច្ឆេទ |
|---|---|
| ______________________ | ______________________ |